[សូមផ្ទៀងផ្ទាត់ តាមការអាន]

បទអន្តរាគមន៍
របស់ អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន
ឧបនាយករដ្ឋមន្ត្រី, រដ្ឋមន្ត្រី ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
និង ជាប្រធានគណៈកម្មាធិការដឹកនាំការងារកែទម្រង់
ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ
ថ្លែងក្នុង
សិក្ខាសាលាស្តីពី កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ

រាជធានីភ្នំពេញ, ថ្ងៃអង្គារ ៥ កើត ខែជេស្ឋ ឆ្នាំរោង ឆស័ក ព.ស. ២៥៦៨
ត្រូវនឹងថ្ងៃទី ១១ ខែ មិថុនា គ.ស. ២០២៤, វេលាម៉ោង ៨:៣០ នាទីព្រឹក, សណ្ឋាគារសុខា

*****+*****

ខ្ញុំសូមគោរព៖

- **ឯកឧត្តមកិត្តិសេដ្ឋាបណ្ឌិត ជាម យៀប**, អនុប្រធានទី ១ នៃរដ្ឋសភា, ជាតំណាងដ៏ខ្ពង់ខ្ពស់ របស់ **សម្តេចមហារដ្ឋសភាធិការធិបតី ឃួន សុដារី** ប្រធានរដ្ឋសភា;
- ឯកឧត្តម **ឈាង វុន** ប្រធានគណៈកម្មការសេដ្ឋកិច្ច, ហិរញ្ញវត្ថុ, ធនាគារ, និង សវនកម្ម នៃរដ្ឋសភា;
- លោកជំទាវបណ្ឌិត **សោម គឹមសួគ៌** អគ្គសវនករ នៃអាជ្ញាធរសវនកម្មជាតិ;
- ឯកឧត្តម, លោកជំទាវ, សមាជិក-សមាជិកា នៃព្រឹទ្ធសភា និង រដ្ឋសភា;
- ឯកឧត្តម, លោកជំទាវ, លោក, លោកស្រី, សមាជិក-សមាជិកា នៃអង្គពិធី, ជាទីមេត្រី !

ថ្ងៃនេះ, ខ្ញុំពិតជាមានកិត្តិយសដ៏ខ្ពង់ខ្ពស់ និង សេចក្តីសោមនស្សរីករាយក្រៃលែង ដោយបានមកចូលរួម និង ធ្វើបទអន្តរាគមន៍ នៅក្នុង **សិក្ខាសាលាស្តីពី កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ** ជូនសមាជិក-សមាជិកា នៃព្រឹទ្ធសភា និង រដ្ឋសភា ដ៏ឧត្តុង្គឧត្តម ។ ពិធីដ៏អធិកអធម នាថ្ងៃនេះ គឺជារបត់ថ្មីមួយទៀតរបស់កម្ពុជា ដែលត្រូវបាន

រៀបចំឡើង នៅដើមអាណត្តិនៃរាជរដ្ឋាភិបាល នីតិកាលទី ៧ នៃរដ្ឋសភា, ក្រោមការដឹកនាំដ៏ត្រឹមត្រូវ, ស្វាហាប់, ឈ្លាសវៃ និង ប៉ិនប្រសព្វ របស់ **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត**, **នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា**, ដែលជាអគ្គមគ្គុទ្ទេសក៍វ័យក្មេងដ៏ឆ្នើម ពោរពេញដោយសមត្ថភាព, ចំណេះដឹង, និង ថាមពល, នៅក្នុងបរិការណ៍ដែលប្រទេសជាតិយើង មានស្ថិរភាពនយោបាយ និង ស្ថិរភាពម៉ាក្រូសេដ្ឋកិច្ចរឹងមាំ ព្រមទាំងការ-អភិវឌ្ឍសង្គម-សេដ្ឋកិច្ច នៅក្រោមម្លប់ដ៏ត្រជាក់នៃសុខសន្តិភាពពេញផ្ទៃប្រទេស ដែល **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**, **អតីតនាយករដ្ឋមន្ត្រី** និង បច្ចុប្បន្នជា **ប្រធានព្រឹទ្ធសភា**, បាននាំមកជូនប្រទេសជាតិ និង ប្រជាជនកម្ពុជា ។

ឆ្លៀតក្នុងឱកាសដ៏វិសេសនេះ, ខ្ញុំសូមអនុញ្ញាតជម្រាបជូនអង្គពិធី ជ្រាបដោយសង្ខេប អំពី សាវតារ, វឌ្ឍនភាព, និង ទស្សនវិស័យ នៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដូចខាងក្រោម ៖

រាជរដ្ឋាភិបាលកម្ពុជា បានចាប់ផ្តើមដាក់ចេញនូវវិធានការកែទម្រង់នានា ចាប់តាំងពីដើមទស្សវត្សរ៍ឆ្នាំ ២០០០ មកម្ល៉េះ ដើម្បីដោះស្រាយបញ្ហាប្រឈម នៃការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ រួមមាន ៖ ភាពពុំរ៉ៃនៃកង្វះសាច់ប្រាក់, ភាពទន់ខ្សោយនៃប្រព័ន្ធគ្រប់គ្រងគណនីទោលរតនាគារជាតិ, កិច្ចប្រតិបត្តិការហិរញ្ញវត្ថុដោយដៃ និង ផ្អែកលើសាច់ប្រាក់, ភាពខ្វះចន្លោះនៃប្រព័ន្ធគណនេយ្យ និង ប្រព័ន្ធរាយការណ៍ ។ល។

ក្នុងបរិការណ៍នោះ, រាជរដ្ឋាភិបាលកម្ពុជា, ក្រោមការដឹកនាំ ប្រកបដោយគតិ-បណ្ឌិតដ៏ខ្ពង់ខ្ពស់ របស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**, បានរៀបចំផ្តួច-ផ្តើមដាក់ឱ្យអនុវត្ត នូវ «**កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ**» មួយដែលមានលក្ខណៈគ្រប់ជ្រុងជ្រោយ និង គ្របដណ្តប់លើគ្រប់ទិដ្ឋភាពនៃប្រព័ន្ធហិរញ្ញវត្ថុសាធារណៈរបស់ជាតិ ។ កម្មវិធីនេះ ត្រូវបានប្រកាសដាក់ឱ្យអនុវត្តជាផ្លូវការ នៅថ្ងៃទី ៥ ខែ ធ្នូ ឆ្នាំ ២០០៤ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ របស់ **សម្តេចតេជោ** ក្នុងឋានៈសម្តេចជា **នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា** នាពេលនោះ ។

ចក្ខុវិស័យនៃកម្មវិធីកែទម្រង់នេះ គឺ៖ **ប្រែក្លាយប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈកម្ពុជា, ពីប្រព័ន្ធផ្តោតលើធាតុចូល និង មានលក្ខណៈមជ្ឈការ, ទៅជាប្រព័ន្ធដែលផ្តោតលើលទ្ធផល ឬ សមិទ្ធកម្ម និង មានលក្ខណៈវិមជ្ឈការ, ស្របតាមស្តង់ដា និង ឧត្តមានុវត្តន៍អន្តរជាតិ ។** កម្មវិធីកែទម្រង់នេះ ផ្តោតសំខាន់លើការពង្រឹងប្រសិទ្ធភាព និង ស័ក្តិសិទ្ធភាព

នៃការគ្រប់គ្រងចំណូល និង ចំណាយថវិការដ្ឋ ដើម្បីធានាប្រសិទ្ធភាព និង ស័ក្តិសិទ្ធភាព ក្នុងការអនុវត្តគោលនយោបាយជាអាទិភាពរបស់រាជរដ្ឋាភិបាល ។

ដើម្បីសម្រេចចក្ខុវិស័យនៃកម្មវិធីកែទម្រង់ខាងលើ, រាជរដ្ឋាភិបាលកម្ពុជា បានកំណត់យកយុទ្ធសាស្ត្រ បោះជំហានតាមដំណាក់កាល ឬ អភិក្រមជាខឿន តាមរយៈក្របខណ្ឌផែនការសកម្មភាពរួមដ៏លម្អិតមួយ ដែលផ្សំឡើងពី ៖ (១).បណ្តាសកម្មភាពចាំបាច់ សម្រាប់ការកសាងមូលដ្ឋានគ្រឹះ នៅតាមដំណាក់កាលនីមួយៗ; និង (២). សកម្មភាពចាំបាច់នានា ដែលត្រូវចាប់ផ្តើមសាកល្បងដកពិសោធន៍ ជាបណ្តើរៗ មុនឈានចូលទៅដល់ដំណាក់កាលបន្ទាប់ ។ ក្នុងនោះ, កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ត្រូវបានបែងចែកជា ៤ ដំណាក់កាល រួមមាន៖

- ដំណាក់កាលទី ១ ផ្តោតលើ **ការកសាងភាពជឿទុកចិត្តនៃថវិកា;**
- ដំណាក់កាលទី ២ ផ្តោតលើ **ការកសាងគណនេយ្យភាពហិរញ្ញវត្ថុ;**
- ដំណាក់កាលទី ៣ ផ្តោតលើ **ការផ្សារភ្ជាប់ថវិកាទៅនឹងគោលនយោបាយ;** និង
- ដំណាក់កាលទី ៤ ផ្តោតលើ **ការកសាងគណនេយ្យភាពសមិទ្ធកម្ម ។**

ការប្រកាន់យកចក្ខុវិស័យ និង យុទ្ធសាស្ត្រខាងលើនេះ បានបង្ហាញអំពីមហិច្ឆតា និង ឆន្ទៈមោះមុត របស់រាជរដ្ឋាភិបាល ក្នុងការប្រែក្លាយប្រព័ន្ធហិរញ្ញវត្ថុសាធារណៈកម្ពុជា ឱ្យឆ្លើយតបបានទៅនឹងតម្រូវការជាក់ស្តែងក្នុងបរិបទនៃប្រទេស ផង និង ធានាបាននូវប្រសិទ្ធភាព និង ស័ក្តិសិទ្ធភាព ក្នុងការគ្រប់គ្រងធនធានហិរញ្ញវត្ថុសាធារណៈរបស់ជាតិស្របតាមឧត្តមានុវត្តន៍អន្តរជាតិ ផង ។ ជាមួយនឹងឆន្ទៈមុតស្រួចឥតរាថយ និង ឥតងាករេ, រាជរដ្ឋាភិបាលកម្ពុជា, ក្នុងនីតិកាលកន្លងទៅ, បានឆ្លងកាត់ដំណាក់កាល ទាំង ៣ នៃការ-កែទម្រង់ហិរញ្ញវត្ថុសាធារណៈ ប្រកបដោយជោគជ័យ ដោយទទួលបានផលផ្លែផ្កា គួរជាទីមោទនៈបំផុត ។

ដំណាក់កាលទី ១ បានចាប់ផ្តើមឡើង នៅចុងឆ្នាំ ២០០៤ ដោយផ្តោតលើ «**ការកសាងភាពជឿទុកចិត្តនៃថវិកា**» ដែលត្រូវបានអនុវត្ត រហូតដល់ឆ្នាំ ២០០៨ ដោយសម្រេចបាននូវសមិទ្ធផលគន្លឹះជាមូលដ្ឋាន សម្រាប់ការបោះជំហានទៅកាន់ដំណាក់កាលបន្ទាប់, ពោលគឺ៖ ការដោះស្រាយបានដោយជោគជ័យ នូវបញ្ហាបំណុលសាច់ប្រាក់ដ៏រ៉ាំរ៉ៃ, ការអនុវត្តពេញលេញ នូវប្រព័ន្ធគណនីទោលរតនាគារជាតិ, ការធ្វើ-ទំនើបកម្មច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ, ការកែទម្រង់កិច្ចលទ្ធកម្មសាធារណៈ,

ការបង្កើតអង្គភាពសវនកម្មផ្ទៃក្នុង ។ល។ ទាំងអស់នេះ គឺជាមូលដ្ឋានគ្រឹះដ៏ចាំបាច់ និងជាបុរេលក្ខខណ្ឌ មិនអាចខ្វះបាន សម្រាប់ការចាប់ផ្ដើមដំណាក់កាលទី ២, ដោយផ្ដោតលើ «**ការកសាងគណនេយ្យភាពហិរញ្ញវត្ថុ**», ដែលត្រូវបានអនុវត្តពីឆ្នាំ ២០០៩ ដល់ឆ្នាំ ២០១៥ ។ ដំណាក់កាលទី ២ ត្រូវបានអនុវត្ត ជាដំបូង តាមរយៈក្របខណ្ឌផែនការសកម្មភាព រយៈពេល ៥ ឆ្នាំ, និង បន្ទាប់ពីបានឆ្លងការវាយតម្លៃគ្រប់ជ្រុងជ្រោយ, ត្រូវបានបន្ថែមសកម្មភាព សម្រាប់អនុវត្តរយៈពេលប្រមាណ ២ ឆ្នាំបន្តទៀត ដោយសម្រេចបាននូវសមិទ្ធផលជាសារវ័ន្តមួយចំនួន មានជាអាទិ៍៖ ការបើកផ្ដល់បៀវត្សជូនមន្ត្រីរាជការតាមប្រព័ន្ធធនាគារ, ការពង្រីកអង្គភាពសវនកម្មផ្ទៃក្នុង, ការអភិវឌ្ឍប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (FMIS), និង ការចាប់ផ្ដើមសាកល្បងអនុវត្តប្រព័ន្ធថវិកាកម្មវិធី នៅតាមក្រសួងមួយចំនួន ។

បន្ទាប់ពីត្រូវបានវាយតម្លៃយ៉ាងម៉ត់ចត់ លើវឌ្ឍនភាពរយៈពេល ៧ ឆ្នាំ នៃដំណាក់-កាលទី ២ រួចមក, រាជរដ្ឋាភិបាលបានសម្រេចចាប់ផ្ដើមអនុវត្ត ដំណាក់កាលទី ៣ ដែលជាដំណាក់កាលយុទ្ធសាស្ត្រដ៏សំខាន់មួយទៀត ដោយផ្ដោតលើ «**ការផ្សារភ្ជាប់ថវិកាទៅនឹងគោលនយោបាយ**» ។ ដំណាក់កាលទី ៣ នេះ ត្រូវបានអនុវត្ត ពីឆ្នាំ ២០១៦ ដល់ឆ្នាំ ២០២២ ។ ខ្ញុំសូមរំលឹកថា ដំណាក់កាលទី ៣ គ្រោងបញ្ចប់ ក្នុងឆ្នាំ ២០២០; ប៉ុន្តែ, ដោយសារកត្តាសត្យានុម័ត, ជាពិសេស វិបត្តិជំងឺកូវីដ-១៩, គោលដៅគន្លឹះមួយចំនួនមិនអាចសម្រេចបាន តាមកាលកំណត់នោះឡើយ ដែលជាហេតុតម្រូវឱ្យមានការ-ពន្យារពេលចំនួន ២ ឆ្នាំបន្ថែមទៀត, គឺ ឆ្នាំ ២០២១ ដល់ឆ្នាំ ២០២២ ។

ក្រៅពីការពង្រឹងគណនេយ្យភាពហិរញ្ញវត្ថុ តាមរយៈ ការពង្រីក និង ការពង្រឹង ការ-អនុវត្តថវិកាកម្មវិធី ក៏ដូចជា ការកែលម្អប្រព័ន្ធគណនេយ្យសាធារណៈ និង ប្រព័ន្ធសវន-កម្ម និង អធិការកិច្ចហិរញ្ញវត្ថុ, ជាពិសេស ការចាប់ផ្ដើមដាក់ឱ្យអនុវត្តជាជំហានៗ នូវប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (FMIS), សមិទ្ធ-ផលនៃដំណាក់កាលទី ៣ ក៏រួមបញ្ចូលផងដែរ នូវយុទ្ធសាស្ត្រកែទម្រង់សំខាន់ៗ ដែលជាមូលដ្ឋានគ្រឹះនៃការកសាង «**ប្រព័ន្ធថវិកាព័ត៌មានសមិទ្ធកម្ម**» រួមមាន៖ **យុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធថវិកាជាតិ, យុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធថវិកា របស់រដ្ឋបាលថ្នាក់ក្រោមជាតិ, យុទ្ធសាស្ត្រក្របខណ្ឌចំណាយរយៈពេលមធ្យម, យុទ្ធសាស្ត្រកែទម្រង់ប្រព័ន្ធលទ្ធកម្មសាធារណៈ, យុទ្ធសាស្ត្រស្ដីពីការកែទម្រង់ប្រព័ន្ធគ្រប់គ្រងការវិនិយោគសាធារណៈ,** និង **យុទ្ធសាស្ត្រកែទម្រង់ប្រព័ន្ធគណនេយ្យ** ។

ទន្ទឹមនេះ, ច្បាប់គោលសំខាន់ៗ សម្រាប់ប្រើប្រាស់ជាមូលដ្ឋាន ក្នុងការធ្វើឱ្យកាន់-តែប្រសើរឡើង នូវការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ក៏ត្រូវបានអនុម័ត និង ដាក់ឱ្យប្រើ-ប្រាស់ មានជាអាទិ៍ ៖ **ច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ (ថ្មី) ឆ្នាំ ២០២៣, ច្បាប់ស្តីពីសារពើពន្ធ (ថ្មី) ឆ្នាំ ២០២៣, ច្បាប់ស្តីពីការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ ឆ្នាំ ២០២២, ច្បាប់ស្តីពីការគ្រប់គ្រង ការប្រើប្រាស់ និង ការចាត់ចែង លើទ្រព្យសម្បត្តិរដ្ឋ ឆ្នាំ ២០២០, ច្បាប់ស្តីពីលទ្ធកម្មសាធារណៈ (ថ្មី) ឆ្នាំ ២០២៣, ច្បាប់ស្តីពីមូលបត្ររដ្ឋ ឆ្នាំ ២០២០,** និង **ច្បាប់ស្តីពីភាពជាដៃគូរវាងរដ្ឋ និង ឯកជន ឆ្នាំ ២០២១** ។

ឯកឧត្តម, លោកជំទាវ, លោក, លោកស្រី !

ជារួម, ការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ក្នុងរយៈពេលប្រមាណ ២០ ឆ្នាំកន្លងទៅនេះ បាននាំមកនូវសមិទ្ធផលជាប្រវត្តិសាស្ត្រជាច្រើនសម្រាប់កម្ពុជា, ទាំងសមិទ្ធផលក្នុងការកែលម្អអភិបាលកិច្ចនៃការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និង ទាំងសមិទ្ធផល ក្នុងទិដ្ឋភាពនៃការរីកចម្រើនផ្នែកសង្គម-សេដ្ឋកិច្ច របស់កម្ពុជា ។ ក្នុងឱកាសនេះ, ខ្ញុំសូមគូសរំលេចនូវ **សមិទ្ធផលគន្លឹះ ចំនួន ៥** ដូចតទៅ ៖

សមិទ្ធផលគន្លឹះទី ១ : **ការកសាងបាននូវភាពជឿទុកចិត្តបាននៃថវិកា** (Budget Credibility) ។ ក្នុងរយៈពេល ៥ ឆ្នាំ ដំបូងនៃការអនុវត្តដំណាក់កាលទី ១ នៃកម្មវិធីកែទម្រង់, ថវិកាជាតិត្រូវបានកែលម្អ ឱ្យមាន «**ភាពជឿទុកចិត្ត**», ដែលទទួលបាននូវការវាយតម្លៃខ្ពស់ពីតួអង្គពាក់ព័ន្ធទាំងអស់, ទាំងប្រជាពលរដ្ឋ, មន្ត្រីរាជការ, និង ស្ថាប័នហិរញ្ញវត្ថុជាតិ និង អន្តរជាតិ, តាមរយៈកិច្ចប្រឹងប្រែងកៀរគរចំណូល, ជាពិសេស ការពង្រឹងស្ថាប័ន និង ការធ្វើទំនើបកម្មរដ្ឋបាលសារពើពន្ធ; ការកែទម្រង់លើការព្យាករណ៍ចំណូល និង ការប៉ាន់ស្មានចំណាយ, ប្រចាំត្រីមាស និង ប្រចាំឆ្នាំ; ការលើកកម្ពស់តម្លាភាពថវិកា; ការធ្វើផែនការថវិកា; ការកែលម្អប្រព័ន្ធកត់ត្រា ក៏ដូចជា ប្រព័ន្ធរាយការណ៍ និង ការពង្រឹងការគ្រប់គ្រងសាច់ប្រាក់ជាដើម ។ ទាំងអស់នេះ សុទ្ធសឹងជាសមាសធាតុគន្លឹះ ដែលរួមចំណែកដល់ការបង្កើនទំហំ និង ការពង្រឹងការគ្រប់គ្រងចំណូលថវិការដ្ឋ ព្រមទាំងការលើកកម្ពស់ប្រសិទ្ធភាព ក្នុងការ-គ្រប់គ្រងចំណាយ ។

សមិទ្ធផលគន្លឹះទី ២ : **ការកសាងបានជាមូលដ្ឋាន នូវ សមាសធាតុចាំបាច់ទាំង-ឡាយនៃប្រព័ន្ធថវិកាទំនើប ដែលឆ្លើយតបនឹងឧត្តមានុវត្តជាអន្តរជាតិ** ។ ក្នុងរយៈពេល ២០ ឆ្នាំកន្លងទៅនេះ, ប្រព័ន្ធថវិការបស់កម្ពុជា ត្រូវបានកែប្រែ, ពីប្រព័ន្ធដែលការខ្វះចន្លោះជាច្រើន,

មកជាប្រព័ន្ធដែលមានសមាសធាតុគ្រប់ជ្រុងជ្រោយ, ដោយចាប់ផ្តើមពីដំណាក់កាលដំបូងនៃការធ្វើឱ្យថវិកាមាន **«ភាពជឿទុកចិត្ត»**; បន្ទាប់មក, ក្នុងដំណាក់កាលទី ២ គឺការបន្តពង្រឹង **«គណនេយ្យភាពហិរញ្ញវត្ថុ»**; ហើយបន្តមកទៀត, ក្នុងដំណាក់កាលទី ៣ គឺការសម្រេចបានជាសារវន្ត នូវសមាសធាតុគន្លឹះទាំងឡាយនៃ **«ការផ្សារភ្ជាប់ថវិកាទៅនឹងគោលនយោបាយ»** តាមរយៈការអនុវត្តថវិកាកម្មវិធី សំដៅធ្វើឱ្យថវិការបស់ជាតិ កាន់តែផ្លាស់ប្តូរ ទៅជាថវិកាបែបវិមជ្ឈការ និង ផ្តោតលើលទ្ធផល និង សមិទ្ធកម្ម ។ ខាងទិដ្ឋភាពឌីជីថល, ការគ្រប់គ្រងថវិកា, ទាំងថវិកាថ្នាក់ជាតិ និង ថវិកាថ្នាក់ក្រោមជាតិ, ក៏ត្រូវបានផ្លាស់ប្តូរជាបណ្តើរៗ ទៅកាន់ការគ្រប់គ្រងតាមរយៈ **ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ** (FMIS) ។ ក្នុងន័យនេះ, បើពិនិត្យលើវដ្តថវិកា (Budget cycle), ទាំងក្នុងដំណាក់កាលរៀបចំថវិកា, អនុម័តថវិកា, អនុវត្តថវិកា, ត្រួតពិនិត្យថវិកា, តាមដានថវិកា, និង វាយតម្លៃថវិកា, ប្រព័ន្ធថវិការបស់យើង មានសមាសធាតុចាំបាច់គ្រប់គ្រាន់, ទាំងលើទិដ្ឋភាពស្ថាប័ន, ប្រព័ន្ធគ្រប់គ្រង, ក្របខណ្ឌគតិយុត្ត, យន្តការ, និង ធនធានមនុស្ស, ដែលធ្វើឱ្យស្ថាប័នរដ្ឋមានសមត្ថភាព អាចឆ្លើយតបបានកាន់តែប្រសើរឡើង ទៅនឹងបញ្ហានានា, ជាពិសេស នៅពេលមានវិបត្តិដែលមិនអាចស្មានទុកជាមុនបាន ។ ថ្មីៗនេះ, កាលពីខែ មេសា ឆ្នាំ ២០២៤, ក្របខណ្ឌហិរញ្ញវត្ថុសាធារណៈរយៈពេលមធ្យម ឆ្នាំ ២០២៥-២០២៧ ក៏ត្រូវបានរៀបចំ និង ដាក់ឱ្យអនុវត្ត ដែលជាសមាសភាគដ៏សំខាន់មួយទៀត បំពេញបន្ថែមដល់វដ្តថវិកា ឲ្យមានភាពកាន់តែគ្រប់ជ្រុងជ្រោយ ។

សមិទ្ធផលគន្លឹះទី ៣ : **រាជរដ្ឋាភិបាលបានត្រៀមលក្ខណៈរួចរាល់ សម្រាប់ការចាប់យក «ប្រព័ន្ធថវិកាផ្អែកលើសមិទ្ធកម្ម»** ដែលជាគោលដៅចុងក្រោយនៃកម្មវិធីកែទម្រង់ការ-គ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ តាមរយៈការសម្រេចឱ្យបាន នៅក្នុងដំណាក់កាលទី ៤ (២០២៣-២០២៧) នូវ **«គណនេយ្យភាពសមិទ្ធកម្ម»** ដែលមានន័យថា **ជាការទទួលខុសត្រូវលើលទ្ធផលចុងក្រោយ** ស្របគ្នានឹងការប្រែប្រួលជាសារវ័ន្តនៃផ្នែកគោលនយោបាយ និង យុទ្ធសាស្រ្តអាទិភាព សំដៅពង្រឹងប្រសិទ្ធភាព, គុណភាព និង ការទទួលខុសត្រូវ លើលទ្ធផលនៃការអនុវត្តរបស់ស្ថាប័នសាធារណៈ និង មន្ត្រីរាជការ ក្នុងក្របខណ្ឌរាជរដ្ឋាភិបាលទាំងមូល ។ ក្នុងន័យនេះ, សម្រាប់កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ, ជាមួយនឹងការទទួលបាននូវការផ្ទេរសិទ្ធិអំណាច ក្នុងការគ្រប់គ្រងធនធានហិរញ្ញវត្ថុរបស់ខ្លួន, ក្រសួង-ស្ថាប័ននីមួយៗ នឹងត្រូវមានការទទួលខុសត្រូវខ្ពស់ លើការប្រើប្រាស់ថវិកា ឱ្យបានប្រកបដោយប្រសិទ្ធភាព, ស័ក្តិសិទ្ធភាព, និង ចំគោលដៅ, ពោលគឺ, ម្ចាង, ត្រូវទទួលខុសត្រូវ

លើការសម្រេចឱ្យបាន នូវគោលបំណងគោលនយោបាយ, បេសកកម្ម និង សូចនាករលទ្ធផលរំពឹងទុករបស់ខ្លួន ដោយអនុលោមតាមគោលការណ៍នៃ «**ការផ្សារភ្ជាប់ថវិកាទៅនឹងគោលនយោបាយ**»; និង ម្ខាងទៀត, ត្រូវទទួលខុសត្រូវយ៉ាងម៉ឺងម៉ាត់ លើការប្រើប្រាស់ថវិកាដែលត្រូវបានអនុម័តផ្តល់ជូន ឱ្យបានប្រកបដោយប្រសិទ្ធភាព, តម្លាភាព, និង គណនេយ្យភាព ព្រមទាំងធានាបាននូវ «**តម្លៃនៃលុយ**» ស្របតាមបទប្បញ្ញត្តិនៃការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ជាធរមាន ។

សមិទ្ធផលគន្លឹះទី ៤ : ការសម្រេចបាននូវកំណើនសេដ្ឋកិច្ចដ៏រឹងមាំ និង ប្រកបដោយភាពធន់ និង ចីរភាព ក្នុងរយៈពេលវែង ។ បើគិតចាប់ពីឆ្នាំ ២០០៤ មក, កម្ពុជាមានកំណើនសេដ្ឋកិច្ចល្អ, ក្នុងរង្វង់ ៧% ក្នុងមួយឆ្នាំ, ជាមួយនឹងការរក្សាបាននូវអត្រាអតិផរណាទាប, ក្នុងរង្វង់ ៣% ប្រចាំឆ្នាំ, និង អត្រាប្តូរប្រាក់មានស្ថិរភាព, លើកលែងតែក្នុងអំឡុងនៃវិបត្តិជំងឺកូវីដ-១៩ ជាសកល ប៉ុណ្ណោះ, ដែលកំណើនមានការធ្លាក់ចុះស្ទើរគ្រប់ប្រទេស ទូទាំងសកលលោក រួមទាំងកម្ពុជា ផង ។ ជាការពិត, បន្ទាប់ពីស្ថានភាពនៃវិបត្តិជំងឺកូវីដ-១៩ បានថមថយ, ទោះបីជាសេដ្ឋកិច្ចសកល នៅបន្តជួបនឹងបញ្ហាប្រឈម និង ភាពមិនប្រាកដប្រជាខ្ពស់យ៉ាងណាក្តី, ក៏សេដ្ឋកិច្ចកម្ពុជា បានស្ទុះងើបឡើងវិញយ៉ាងរហ័ស មករកអត្រាកំណើនជាសក្តានុពលឡើងវិញ ។ ជាក់ស្តែង, សេដ្ឋកិច្ចកម្ពុជា ក្នុងឆ្នាំ ២០២៣ កន្លងទៅ ត្រូវបានវាយតម្លៃថា សម្រេចបានកំណើន ក្នុងអត្រាប្រមាណ ៥%, ហើយសម្រាប់ឆ្នាំ ២០២៤ នេះ, ត្រូវបានព្យាករណ៍ថា នឹងបន្តស្ទុះឡើង ក្នុងអត្រាប្រមាណ ៦% ។ ច្បាស់ណាស់ថា កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ បានដើរតួដ៏សំខាន់ ក្នុងការរួមចំណែកធ្វើឱ្យសេដ្ឋកិច្ចកម្ពុជា មានភាពរឹងមាំយ៉ាងដូច្នេះ ។ ជារួម, លទ្ធផលដ៏ល្អនៅក្នុងការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ គឺជាឃ្នាស់សេដ្ឋកិច្ចដ៏សំខាន់បំផុតមួយ ដែលធ្វើឱ្យកម្ពុជាសម្រេចបានកំណើនសេដ្ឋកិច្ចខ្ពស់ និង បន្តស្ថិរភាពនៃកំណើន ជាបន្តបន្ទាប់ រហូតសម្រេចបាននូវចំណាត់ថ្នាក់ជា **ប្រទេសមានចំណូលមធ្យមកម្រិតទាប** នៅឆ្នាំ ២០១៥, ហើយបន្តជម្នះបានដោយជោគជ័យ នូវវិបត្តិផងទាំងពួង និង កំពុងបោះជំហានប្រកបដោយភាពជឿជាក់ទៅកាន់ឋានៈជា **ប្រទេសមានចំណូលមធ្យមកម្រិតខ្ពស់ នៅឆ្នាំ ២០៣០** និង ជា **ប្រទេសមានចំណូលខ្ពស់ នៅឆ្នាំ ២០៥០** ។ សមិទ្ធកម្មដ៏ប្រសើរនេះ ក៏បានផ្តល់លទ្ធភាពកាន់តែខ្ពស់ ជូនរាជរដ្ឋាភិបាល ក្នុងការលើកកម្ពស់កម្រិតជីវភាពរបស់ប្រជាពលរដ្ឋទូទៅ ក៏ដូចជា លើកកម្ពស់ជីវភាព និង គុណភាពរបស់មន្ត្រីរាជការ, ពង្រឹងប្រសិទ្ធភាពស្ថាប័នសាធារណៈ, និង បម្រើសេវាសាធារណៈជូនប្រជាពលរដ្ឋ បានកាន់តែល្អឡើងជាលំដាប់ ។

សមិទ្ធផលគន្លឹះទី ៥ : **ការពង្រឹងឯករាជ្យជាតិ និង អធិបតេយ្យជាតិ ។** ក្នុងបុព្វហេតុឯករាជ្យ និង អធិបតេយ្យជាតិ, សមិទ្ធកម្មដ៏ល្អនៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ បានពង្រឹងឱ្យកាន់តែមាំមួនឡើង នូវភាពជាម្ចាស់ និង តួនាទីរបស់រាជរដ្ឋាភិបាលកម្ពុជា ក្នុងការទទួលខុសត្រូវលើជោគវាសនារបស់ប្រទេសជាតិ ដោយបានកាត់បន្ថយការពឹងផ្អែកលើការខ្ចីពីក្រៅប្រទេស ។ បច្ចុប្បន្ន, ការខ្ចីពីក្រៅប្រទេសប្រចាំឆ្នាំ មានទំហំមិនដល់ ២០ ភាគរយនៃថវិកាជាតិសរុប នោះទេ ។ ផ្ទុយទៅវិញ, កាលពីអតីតកាល ប្រមាណ ៣០ ឆ្នាំមុន, ចំណូលក្នុងស្រុកដែលយើងរកបានដោយខ្លួនឯង មានត្រឹមប្រមាណមួយភាគបីនៃចំណូលថវិកាជាតិសរុប តែប៉ុណ្ណោះ; នេះបានន័យថា ប្រមាណពីរភាគបីនៃតម្រូវការចំណាយថវិកាជាតិ ត្រូវបានដោះស្រាយដោយប្រភពធនធាន ជាជំនួយហិរញ្ញវត្ថុពីក្រៅប្រទេស ។

ឯកឧត្តម, លោកជំទាវ, លោក, លោកស្រី !

នៅពេលនេះ, កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ របស់រាជរដ្ឋាភិបាល បានឈានដល់ការអនុវត្តក្នុងដំណាក់កាលចុងក្រោយ, ពោលគឺ ដំណាក់កាលទី ៤, ផ្តោតលើ «**គណនេយ្យភាពសមិទ្ធកម្ម**», ដែលត្រូវបានប្រកាសដាក់ឱ្យអនុវត្ត ដោយ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** កាលពីថ្ងៃទី ២០ ខែ មីនា ឆ្នាំ ២០២៣, ដោយត្រូវអនុវត្តរហូតដល់ឆ្នាំ ២០២៧ ។ ថ្វីត្បិតដំណាក់កាលទី ៤ នៃកម្មវិធីកែទម្រង់ ទើបតែត្រូវបានអនុវត្តក្នុងរយៈពេល ១ ឆ្នាំជាង, មូលដ្ឋានគន្លឹះឈានទៅកាន់ «**គណនេយ្យភាពសមិទ្ធកម្ម**» ក៏ដូចជា វប្បធម៌សមិទ្ធកម្មក្នុងរដ្ឋបាលសាធារណៈ បាន និង កំពុងមានវឌ្ឍនភាព គួរឱ្យកត់សម្គាល់ ។ ជាក់ស្តែង, ថវិកាព័ត៌មានសមិទ្ធកម្ម និង កិច្ចព្រមព្រៀងសមិទ្ធកម្ម ត្រូវបានដាក់ឱ្យអនុវត្តសាកល្បងជាបណ្តើរៗ ចាប់ពីឆ្នាំ ២០២៣ មក; ហើយក្នុងឆ្នាំ ២០២៥ ខាងមុខ, គ្រប់ក្រសួង-ស្ថាប័ននឹងត្រូវអនុវត្តសាកល្បង នូវកិច្ចព្រមព្រៀងសមិទ្ធកម្មនេះ ។ ការអនុវត្តសាកល្បងនូវកិច្ចព្រមព្រៀងនេះ ត្រូវបានកំណត់ជា ៣ កម្រិត រួមមាន៖ **ទី១).**រវាងក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ជាមួយក្រសួង-ស្ថាប័នសាមី; **ទី២).** រវាងរដ្ឋមន្ត្រីក្រសួង និង ប្រធានស្ថាប័ន ជាមួយនឹងអ្នកគ្រប់គ្រងកម្មវិធី នៅតាមក្រសួង-ស្ថាប័នសាមី; និង **ទី៣).** រវាងអ្នកគ្រប់គ្រងកម្មវិធី ជាមួយនឹងប្រធានអង្គភាពថវិកា ។ មួយវិញទៀត, នៅក្នុងទិដ្ឋភាពនៃការលើកកម្ពស់តម្លាភាពថវិកា និង ការចូលរួមរបស់សាធារណជន, កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ បានជំរុញការផ្សព្វផ្សាយឯកសារថវិកា តាមរយៈវិធានការកែទម្រង់មួយចំនួន ដូចជា ៖ ការផ្សព្វផ្សាយសេចក្តីព្រាង

ច្បាប់ថវិកា បន្ទាប់ពីត្រូវបានបញ្ជូនទៅដល់រដ្ឋសភា, ការរៀបចំវេទិកាសាធារណៈ, ការរៀបចំ និង ការផ្សព្វផ្សាយ សៀវភៅសង្ខេបនៃច្បាប់ថវិកាប្រចាំឆ្នាំ, ព្រមទាំង ការរៀបចំ និង ការ-ផ្សព្វផ្សាយ សៀវភៅសង្ខេបនៃរដ្ឋបាលថ្នាក់ក្រោមជាតិ ។ ជាលទ្ធផល, សន្ទស្សន៍នៃតម្លាភាពថវិការបស់កម្ពុជា មានការកើនឡើងជាបន្តបន្ទាប់, ពោលគឺ ចាប់ពី ២០ ពិន្ទុ (២០/១០០) ក្នុងឆ្នាំ ២០១៧, រហូតដល់ ៣៣ ពិន្ទុ (៣៣/១០០) ក្នុងឆ្នាំ ២០២១, និង បានបន្តកើនដល់ ៤៣ ពិន្ទុ (៤៣/១០០) ក្នុងឆ្នាំ២០២៣, ផ្អែកតាមលទ្ធផលនៃការអង្កេតលើការបើកចំហថវិកា (Open Budget Survey - OBS) ។ ជាមួយគ្នានេះ, នៅក្នុងគោលដៅគណនេយ្យភាពសមិទ្ធកម្ម, តួនាទីតាមដាន និង ត្រួតពិនិត្យថវិការដ្ឋពីសំណាក់ស្ថាប័ននីតិប្បញ្ញត្តិ, ជាស្ថាប័នតំណាងប្រជាជន, នឹងកាន់តែមានសារៈសំខាន់ ក្នុងប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ខណៈដែលប្រព័ន្ធថវិការបស់យើង ត្រូវបានកែលម្អ ជាបន្តបន្ទាប់ ។ ឧទាហរណ៍, ជាទិសដៅរយៈពេលវែងនៃការកែទម្រង់ប្រព័ន្ធថវិកា, ស្របតាមការកំណត់នៃច្បាប់ស្ដីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ ឆ្នាំ ២០២៣, ក្នុងដំណាក់កាលពិនិត្យ និង អនុម័តថវិកា, រដ្ឋមន្ត្រីក្រសួង និង ប្រធានស្ថាប័ន ត្រូវទទួលខុសត្រូវលើកញ្ចប់ថវិកាប្រចាំឆ្នាំ និង សមិទ្ធកម្មរបស់ខ្លួនដោយផ្ទាល់ជាមួយនឹងស្ថាប័ននីតិប្បញ្ញត្តិ ។

សរុបជារួម, ផ្អែកលើវឌ្ឍនភាព ដែលបាន និង កំពុង លេចរូបរាងឡើង តាំងពី **ដំណាក់កាលទី ១** មកដល់ **ដំណាក់កាលទី ៤** នេះ, យើងអាចវាយតម្លៃបានថា ប្រព័ន្ធហិរញ្ញវត្ថុសាធារណៈរបស់កម្ពុជា កំពុងធ្វើដំណើរនៅលើវិថី ឆ្ពោះទៅកាន់ស្តង់ដា និង ឧត្តមានុវត្តន៍អន្តរជាតិ ដែលធានាបាននូវ ប្រសិទ្ធភាព, ស័ក្តិសិទ្ធភាព, តម្លាភាព, និង គណនេយ្យភាព ក្នុងបរិបទកម្ពុជា ហើយមានភាពបត់បែន និង ធន់ទៅនឹងការប្រែប្រួលនៃស្ថានភាពសង្គម-សេដ្ឋកិច្ច នៃសកលលោក ។

ឯកឧត្តម, លោកជំទាវ, លោក, លោកស្រី !

មុននឹងបញ្ចប់, ខ្ញុំសូមយកឱកាសដ៏ថ្លៃថ្លានេះ ថ្លែងអំណរគុណដ៏ជ្រាលជ្រៅ ដល់ថ្នាក់ដឹកនាំ នៃរដ្ឋសភា និង ព្រឹទ្ធសភា ព្រមទាំងថ្នាក់ដឹកនាំ និង មន្ត្រីរាជការ នៃអគ្គលេខាធិការដ្ឋានរដ្ឋសភា ដែលបានសម្របសម្រួលរៀបចំសិក្ខាសាលាដ៏មានសារៈសំខាន់នេះឡើង ។

ខ្ញុំសង្ឃឹមយ៉ាងមុតមាំថា ក្រោមម្លប់ដ៏ត្រជាក់នៃ «**សុខសន្តិភាព**» និង «**ស្ថិរភាព**» គួបផ្សំនឹងការរួមគ្នាជាធ្លុងមួយ ព្រមទាំងការឧទ្ទិសនូវកម្លាំងកាយ-ចិត្ត និង ប្រាជ្ញា-ស្មារតី ក្នុងឆន្ទៈមោះមុតឥតរាថយ ចំពោះកិច្ចការកែទម្រង់, ស្ថាប័ននីតិប្រតិបត្តិ និង ស្ថាប័ននីតិ-

ប្បញ្ញត្តិ ក្នុងនីតិកាលទី ៧ នេះ នឹងសម្រេចបាននូវជោគជ័យថ្មីជាច្រើនបន្ថែមទៀត ដើម្បីបម្រើជាឧត្តមប្រយោជន៍ជូនដល់ប្រទេស និង ប្រជាជនកម្ពុជាយើង ។ ខ្ញុំសូមឧទ្ទិសសិក្ខាសាលា នាថ្ងៃនេះ ជាវេទិកាផ្លាស់ប្តូរមតិយោបល់ និង ចែករំលែកបទពិសោធន៍ លើវឌ្ឍនភាព និង ទិសដៅ នៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ រវាងស្ថាប័ននីតិប្បញ្ញត្តិ និង ស្ថាប័ននីតិប្រតិបត្តិ ដែលខ្ញុំរំពឹងថា នឹងរួមចំណែកដ៏សំខាន់ ដល់ការពង្រឹងឲ្យកាន់តែភ្លៀវភ្លាឡើងបន្ថែមទៀត នូវចលនការ និង ជវភាពនៃកិច្ចអភិវឌ្ឍជាតិ ឆ្លើយតបទៅនឹងបំណងប្រាថ្នាដ៏ពិសិដ្ឋ របស់ប្រជាជនយើង ។

ជាទីបញ្ចប់, ខ្ញុំសូមប្រសិទ្ធពរជ័យជូន **ឯកឧត្តម, លោកជំទាវ, លោក, លោកស្រី,** សមាជិក-សមាជិកាទាំងអស់នៃអង្គពិធី បានប្រកបដោយពុទ្ធពរ និង ពរ ទាំង ៥ ប្រការ គឺៈ **អាយុ, វណ្ណៈ, សុខៈ, ពលៈ, និង បដិភាណៈ** កុំបីឃ្លៀងឃ្លាតឡើយ ៕

ខ្ញុំសូមអរគុណ ចំពោះការយកចិត្តទុកដាក់ !